N"04_JS_Ver 5_Single.qxd 06/16/2006 10:35 Morning Page I

# ព្រាបសន្តិភាព ២00៥

ព្រឹត្តិបត្រ ព្រាបសន្តិភាព | អ្វីៗដើម្បីសន្តិភាព | ឆ្នាំទី២ លេខ 0៤ កុម្ភៈ

## តើព្រះមហាឃោសនន្ទ ជាអ្នកណា?

ព្រះមហាឃោសនន្ទសម្តេចសង្ឃ គឺស្វែងរកសន្តិភាពសំរាប់មនុស្សទូទៅព្រះអង្គមានសកម្មភាពចាប់តាំងពីឆ្នាំ១៩៧៨ក្នុងធម្មទេសនាធម្មយាត្រានិងជាអ្នកនាំសន្តិភាពនៅក្នុងប្រទេសកម្ពុជាតាមបណ្តាសហគមន៍ជនភៀសខ្លួនតាំងពីឆ្នាំ ១៩៩១ ក្នុងព្រះរាជាណាចក្រកម្ពុជា។ សកម្មភាពរបស់ព្រះអង្គពោរពេញទៅដោយការអត់ធ្មត់និងបូជាគ្រប់យ៉ាងដើម្បីសន្តិភាព



ព្រះមហាឃោសនន្ទ សម្តេចសង្ឃខាងស្វែងសន្តិភាព

ព្រះអង្គប្រសូតនៅឆ្នាំ១៩២៤ ខេត្តតាកែវ នៃព្រះរាជាណាក្រកម្ពុជា ព្រះអង្គចូលបួសឆ្នាំ១៩៤៣ ។ សន្តិភាពនិងពន្លឺនៃក្តីសង្ឃឹមមួយជំហានម្តងមួយជំហានម្តង ជំហានទីមួយជាសមាធិជំហានទីមួយៗជាសច្ចានិដ្ឋានជំហានទីមួយៗគឺជាការកសាងស្ពាន។ ព្រះមហាឃោសនន្ទប្រធានអន្តរសាសនាដើម្បីសន្តិភាពកម្ពុជានិងសកលលោកទាំងមូល ។ នៅរសៀលថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៩៣ មានព្រះសង្ឃ ដូនជី ឧបាសកឧបាសិកា ប្រមាណ៤00នាក់ស្ម័គ្រចិត្តធ្វើធម្មយាត្រាជំហាន *តទៅទំព័រទី២*

### មាតិកា


តើមហាឃោសនន្ទជានណា?

ការប្រជុំលើកគំរោងផ្នែកអប់រំ ២00៥

ព្រះជីវប្រវត្តសម្តេចព្រះសង្ឃ ជួន ណាត

រឿងការមិនស្តាប់បង្គាប់ឪពុកម្តាយ

(ភាគបញ្ចប់)


## ការប្រជុំក្រុមអប់រំនិងធ្វើទស្សនកិច្ចតាមសាលារបស់អង្គការJS ឆ្នាំ២00៥

បុគ្គលិកផ្នែកអប់រំអង្គការJS ប្រមាណជា១៥នាក់មកពីសាខាតាមខេត្តមានការប្រជុំ ចែកបទពិសោធន៍ រកវិធីដោះស្រាយបញ្ហានិងសិក្សាទៅលើគំរោងមួយចំនួនដែលត្រូវយកមកអនុវត្តន៍ដើម្បីលើកកំពស់ការអប់រំសំរាប់ឆ្នាំ២00៥ ។ ក្នុងនោះមានការចូលរួមពីបងស្រី អាន មកពីប្រទេស អូស្ត្រាលី បងស្រីឌេនីស ប្រធានអង្គការ JS នៅកម្ពុជានិងបុគ្គលិកផ្នែកអប់រំទាំងអស់មកពីគ្រប់បណ្តាខេត្តទាំង៤ គឺ ខេត្ត កណ្តាល បាត់ដំបង បន្ទាយមានជ័យ និងខេត្តសៀមរាប។ ការប្រជុំបានប្រព្រឹត្តទៅអស់រយៈពេល៤ថ្ងៃគឺចាប់ពីថ្ងៃទី១៣ដល់ថ្ងៃទី១៦ ខែកុម្ភៈឆ្នាំ២00៥ នៅសណ្ឋាគា ឡេងហេង នាខេត្តបាត់ដំបងក្នុងរយៈពេលនេះកិច្ចប្រជុំមានការផ្លាស់ប្តូរមតិចែកបទពិសោធន៏ក្នុងការងារអប់រំដែលបុគ្គលិកបានធ្វើកន្លងមកហើយ។ បានសិក្សាបន្ថែមនូវវិធីសាស្ត្រថ្មីមួយចំនួនដូចជាៈ ចំនុចអ្វីខ្លះដែលសិស្សចេះ-សិស្សមិនចេះនិងចំនុចអ្វីខ្លះដែលគ្រូអាចធ្វើបាន " ដែលអាចជួយសំរួលក្នុងការតាមដានសិស្សរៀនខ្សោយ សិស្សពូកែ និងរិះរកវិធីសាស្ត្រផ្សេងៗដើម្បីជួយជំរុញនិងលើកទឹកចិត្តសិស្សរៀនខ្សោយក្នុងថ្នាក់។ ក្នុងកម្មវិធីនោះក៏មានការចុះធ្វើទស្សនកិច្ចដើម្បីមើលស្ថានភាពសិស្សបណ្ណាល័យនិងតាមថ្នាក់នីមួយៗនៃសាលាដែលអង្គការJS បានជួយឧបត្ថមដូចជាសាលាបឋមសិក្សាគោជ័រ ពេជចង្វា អនុវិទ្យាល័យនាងឡែម ស្ថិតក្នុងស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង និងសាលាបឋមសិក្សានិមិត្តថ្មីរស្មីមានជ័យអូរ៉ាំងហាងក្នុងស្រុកអូជ្រៅខេត្តបន្ទាយមានជ័យ។ កិច្ចប្រជុំបានបញ្ចប់ដោយបានសំរេចនូវ *តទៅទំព័រទី៣*

N”04_JS_Ver 5_Single.qxd 06/16/2006 10:35 Morning Page II

# តើមហាឃោសនន្ទ...

ទីមួយគឺដើម្បីសន្តិភាពដោយផ្អែកទៅលើកិច្ចព្រមព្រៀងក្រុងបារីស ២៣ តុលាឆ្នាំ១៩៩១។ ធម្មយាត្រានេះដោយចាប់ផ្តើមចេញពីអង្គរវត្តដែលជាបូជនីយដ្ឋានជាតិឆ្ពោះទៅកាន់ទីក្រុងភ្នំពេញក្នុងចំងាយផ្លូវ៣៥០គ.ម ដោយឆ្លងកាត់ខេត្តសៀមរាប កំពង់ធំ កំពង់ចាម។ បញ្ជាក់ថាខេត្តទាំងនេះកំពុងតែមានសង្គ្រាមយ៉ាងក្តៅគគុក។ ធម្មយាត្រាគឺជាការធ្វើដំណើរតាមផ្លូវព្រះធម៌ដើម្បីសន្តិភាពនិងការផ្សះផ្សារគ្នា។ ក្រុមធម្មយាត្រាកំពុងសមាធិក្នុងវត្តដំណាក់ខេត្តសៀមរាប នៅពេលព្រឹកថ្ងៃទី៣ ឧសភាស្រាប់តែមានការបាញ់គ្នាប្រមាណជាបួនម៉ោងពេលនោះមានសមាជិកធម្មយាត្រា៣នាក់ត្រូវរបួស។ គ្រាប់បែកមួយគ្រាប់ហោះកាត់បង្អួចចូលមកកាន់បន្ទប់ហើយធ្លាក់ចុះចំកណ្តាលក្រុមធម្មយាត្រាដែលមានគ្នាប្រហែល២០០នាក់រួមទាំងសម្តេច ព្រះមហាឃោសនន្ទ ផងដែរតែសំណាងល្អគ្រាប់បែកពុំផ្ទុះ។ ដោយធម្មយាត្រានេះមានការចូលរួមពីសំណាក់គ្រិស្តបរិស័ទផងដែរនោះព្រះអង្គទ្រង់មានបន្ទូលថា ”ព្រះពុទ្ធនិងព្រះគ្រីស្តជួយយើង ”ដោយមានការគាំទ្រពីមហាជននិងអ្នកដែលរងរបួសពីមន្ទីរពេទ្យនោះធម្មយាត្រានេះបន្តទៅមុខទៀតដោយគ្មានឈប់មួយថ្ងៃបន្ទាប់មកដោយសារធម្មយាត្រានេះដើម្បីសន្តិភាព មានឡានមួយផ្ទុក ព្រះសង្ឃដូនជី ឧបាសកឧ បាសិកាប្រមាណ ១០០នាក់មកពីភ្នំពេញនិងខេត្តនានាបន្ទាប់មកមានឡានមួយទៀតពីប្រទេសថៃមកដល់មូលហេតុដែលយឺតដោយសារមានការប្រយុទ្ធនៅស្អាត់ពីមុខ ។ ធម្មយាត្រានេះបន្តដំណើរដោយជិះឡានឆ្លងកាត់តំបន់ដែលជាចំនុចក្តៅបន្ទាប់មកទៀតដោយថ្មើរជើង។ ធម្មយាត្រាគឺការធ្វើដំណើរតាមព្រះពុទ្ធបរមគ្រូ ព្រះអង្គធ្លាប់បានដឹកនាំសាវ័ករបស់ព្រះអង្គធ្វើដំណើររបៀបនេះជាង២៥០០ឆ្នាំ កន្លងមកហើយ។ ព្រះអង្គដឹកនាំព្រះសង្ឃសាវ័កមានខ្សែបន្ទាត់ដ៏វែងនិមន្តទៅកាន់ជនបទដើម្បីទេសនាពន្យល់ពីរឿងសន្តិភាពនិងផ្លូវសំរាប់រើខ្លួនចាកចេញពីទុក្ខព្រះសម្មាសម្ពុទ្ធធ្លាប់ធ្វើដំណើរទៅកាន់សមរភូមិដែលកំពុងមានការប្រយុទ្ធគ្នាផងដែរ។ ផ្លូវសំខាន់បានជ្រើសរើសសំរាប់ធ្វើដំណើរនិងកន្លែងដែលកំពុងមានសង្គ្រាមឆាបឆេះ ។ សម្តេចទ្រង់មានបន្ទូលទៅកាន់សមាជិកនៃធម្មយាត្រាថា” យើងត្រូវដើរទៅគ្រប់ទីកន្លែងដែលកំពុងមានបញ្ហា” ពេលនោះដែរ ព្រះតេជគុណ **គីមតេង** ជាព្រះសង្ឃមួយអង្គមាននាទីសំខាន់ក្នុងការដឹកនាំក្បួនធម្មយាត្រាមានពុទ្ធដីកាថាៈ” យើងជាព្រះសង្ឃត្រូវតែបំរើប្រជាពលរដ្ឋរបស់យើងព្រោះយើងរស់បានអាស្រ័យប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋជាឆ្នាំងបាយរបស់យើងព្រោះប្រជាពលរដ្ឋបានចិញ្ចឹមយើង បើប្រជាពលរដ្ឋមានទុក្ខយើងមិនអាចអង្គុយធ្វើសមាធិនៅក្នុងវត្តរបស់យើងបានទេយើងត្រូវតែដើរចូលទៅរកកន្លែងដែលប្រជាពលរដ្ឋកំពុងមានទុក្ខវេទនា កំពុងហូរទឹកភ្នែកកំពុងស្រែកយំ ដើម្បីរំលែកទុក្ខពីប្រជាពលរដ្ឋយើង ដើម្បីជួយជូតទឹកភ្នែកប្រជារាស្ត្រយើងគឺការកសាងស្ពានមួយគឺស្ពានសំរាប់ឆ្លងពីសង្គ្រាមពីទុក្ខវេទនាទៅកាន់សន្តិភាពយើងមិនមែនជាកងរក្សាសន្តិសុខជូនអង្គការសហប្រជាជាតិទេ តែយើងជាអ្នកកសាងសន្តិភាពនិងធ្វើអោយមានសន្តិភាព” ។ ធម្មយាត្រាបានចេញដំណើរចាប់តាំងពីម៉ោង៤ភ្លឺនៅទីក្រុងក៏ដូចជា



មហាឃោសនន្ទអោយពរលើទឹកជានិមិត្តរូបនៃការពន្លត់ភ្លើង

ជនបទដែរប្រជាជនស្ទើរតែគ្រប់គ្រួសារបានឈររង់ចាំនៅខាងក្រៅផ្ទះរបស់គេដោយមានប៉ោតមានទឹកពេញនិងទៀនធូបអុជជាស្រេច។ ព្រះសង្ឃនិងដូនជីដើរពីរជួរតាមដងផ្លូវព្រះសង្ឃនិងដូនជីបានបាចទឹកនិងប្រសិទ្ធិពរជូនអ្នកស្រុកទាំងនោះថាៈ ” សូមអោយអ្នកមានសន្តិភាពក្នុងចិត្តក្នុងគ្រួសារក្នុងភូមិនិងក្នុងប្រទេសយើង” ចំណែកឯអ្នកស្រុកវិញបានយកទឹកចាក់លើជើងព្រះសង្ឃ ដូនជី ដើម្បីអោយដំណើរធម្មយាត្រានេះបានសុខសប្បាយហើយត្រជាក់ដូចទឹកដោយយកធូបដែលកំពុងឆេះជ្រលក់ក្នុងទឹកជានិមិត្តរូបនៃការពន្លត់ភ្លើងសង្គ្រាមមានជនពិការបួងសួងថាៈ ”សូមអោយស្រុកខ្ញុំបានសន្តិភាពឆាប់ៗដើម្បីអោយខ្ញុំបានទៅរស់នៅភូមិករផ្ទះសំបែងវិញ ” ទាហានម្នាក់និយាយថាៈ” យើងមិនចង់សំលាប់អ្នកណាម្នាក់ទេ សូម្បីតែត្រឹមធ្វើគេមានរបួសឡើយហើយសូមកុំអោយនណាម្នាក់បាញ់យើងដែរ” ។ ក្បួនដង្ហែរបានមកដល់ទីក្រុងភ្នំពេញដូចគោលបំណងហើយក្បួនធម្មយាត្រានេះមានការចូលរួមកាន់តែច្រើនឡើងៗដោយរួមទាំងសមាគមនិស្សិតបញ្ញវ័ន្តខ្មែរ សមាគមន៏ការពារសិទ្ធិមនុស្ស អង្គការខេមរាផងដែរ។ នៅពីមុខព្រះបរមរាជវាំងអ្នកធ្វើធម្មយាត្រាបានធ្វើសមាធិ ពេលនោះសម្តេចព្រះ **នរោត្តម សីហនុ**

N"04_JS_Ver 5_Single.qxd 06/16/2006 10:35 Morning Page III



*សង្គ្រាមដើម្បីទទួលនូវការរស់នៅដោយសេចក្តីសុខសាន្តជាអមតៈ*

បានយាងបដិសណ្ឋារកិច្ចក្បួនធម្មយាត្រាជាមួយនិងសេចក្តីថ្លែងការណ៏អបអរសាទរយ៉ាងជ្រាលជ្រៅដល់ធម្មយាត្រាហើយទ្រង់បានអំពាវនាវដល់គ្រប់គណបក្សទាំងអស់អោយបញ្ឈប់នូវអំពើហិង្សានិងការស្អប់ខ្ពើមគ្នាហើយបំបាត់ចោលនូវគំនិតសងសឹកគ្នា។ នៅខែមិនាចាប់តាំងពីថ្ងៃទី១០ដល់ ថ្ងៃទី៣១ឆ្នាំ២០០៥ ខាងមុខនេះមជ្ឈមណ្ឌលធម្មយាត្រានិងរៀបចំធ្វើធម្មយាត្រាលើកទី១៥ក្នុងគោលបំណងប្រាំចំនុចគឺអំពីសិទ្ធិមនុស្ស (សិសប្រាំ) បរិស្ថានធម្មជាតិ មច្ឆាជាតិ បឹងទន្លេសាប លើកទឹកចិត្តអ្នកផ្ទុកមេរោគអេដស៏ គ្រោះថ្នាក់ការប្រើគ្រឿងញៀន។ *By TinTin*

# ការប្រជុំស្វែងរក..

គំរោងថ្មីចំនួនបីសំរាប់ឆ្នាំ២០០៥ ដូចជា ទីមួយ បុគ្គលិកផ្នែកអប់រំ ដែលបំរើការអោយអង្គការ JS ទាំងអស់និងមានការប្រជុំនៅដើម ខែមេសា ឆ្នាំ២០០៥នៅក្រុងព្រះសីហនុ ទីពីរចាត់តាំងអ្នកផ្តល់ពតិមានដែលទាក់ទងនិងការអប់រំត្រូវផ្តល់យ៉ាងទៀងទាត់រាល់មួយខែម្តងដើម្បីធ្វើជាព្រឹត្តិបត្រអប់រំមានៈ **លោក ហមសុខ** (បន្ទាយមានជ័យ) **លោក អែម សុម៉ាលី** (សៀមរាប)
**អ្នកស្រី ឆម ស្រីមុំ**(បាត់ដំបង)
**លោកសូណុត** (ភ្នំពេញ) *ដោយណុត*

# ព្រះជីវប្រវត្តិសម្តេចព្រះសង្ឃ ជួន ណាត

ព្រាបសន្តិភាពសូមលើកតែយកសកម្មភាពសំខាន់ៗរបស់សម្តេច ជួន ណាត

១៩២៦ តមកជាច្រើនឆ្នាំសម្តេចទ្រង់បានទទួលការតែងតាំងនាមប្រយោគក្នុងការប្រឡងយកវិញ្ញាបនប័ត្របឋមសិក្សាខ្មែរនិងការប្រឡងយកសញ្ញាប័ត្របឋមសិក្សាជាន់ខ្ពស់បារាំងខ្មែរនៅក្រុងភ្នំពេញ។

១៩២៧សម្តេចទ្រង់បានទទួលការតែងតាំងជាសមាជិកក្រុមជំនុំផ្ទៀងសម្រេចខាងវចនានុក្រមខ្មែរហើយសម្តេចទ្រង់បានទទួលភារៈធ្វើវចនានុក្រមតែមួយព្រះអង្គដរាបដល់បានចប់សព្វគ្រប់បានបោះពុម្ពផ្សាយទាំងភាគ១ ភាគ២ បាន៥គ្រាហើយ។ក្នុងឆ្នាំនេះសម្តេចបានទទួលការតែងតាំងជាសមាជិកនៃក្រុមអភិបាលជំនុំផ្តាច់ឆ្នាំសម្រាប់បណ្ណាល័យកម្ពុជាដែលសព្វថ្ងៃហៅថាវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ។ ១៩៣០សម្តេចទ្រង់បានទទួលការតែងតាំងក្នុងមុខតំណែងជាចាងហ្វាងរងនៃសាលាបាលីជាន់ខ្ពស់ក្រុងភ្នំពេញ។ ក្នុងឆ្នាំដដែលនោះសម្តេចបានទទួលការតែងតាំងជាសមាជិកជំនួយនៃក្រុមជំនុំខាងការស្រាវជ្រាវជ្រើសរើសពាក្យពេចន៏ក្នុងផ្ទៃនៃកវីនិពន្ធខ្មែរបុរាណដើម្បីប្រមូលបញ្ចូនពាក្យទាំងនេះទៅក្នុងវចនានុក្រមខ្មែរ

១៩៣៤ សម្តេចទ្រង់បានទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំជ្រើសរើសពាក្យខ្មែរប្រៀបធៀបនឹង ពាក្យបារាំងសំរាប់ ប្រើក្នុងការងាររាជការ។

១៩៣៥ សម្តេចទ្រង់បានទទួលការតែងតាំងជាសាស្ត្រាចារ្យបង្រៀនភាសាបាលី សំស្ក្រឹតខ្មែរ និង លាវ ប្រចាំថ្នាក់ទីបំផុតនៃមធ្យមសិក្សានៅវិទ្យាលយ័ ព្រះស៊ីសុវត្ថិ ក្រុងភ្នំពេញ។

១៩៤២សម្តេចទ្រង់បាន់ទទួលឋានន្តរជាចាងហ្វាងនៃសាលាបាលីជាន់ខ្ពស់ក្រុងភ្នំពេញដែលសព្វថ្ងៃកែឈ្មោះជាពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត។

១៩៤៤ សម្តេចទ្រង់បានទទួលដំណែងជាចៅអធិការវត្តឧណ្ណាលោម។

១៩៤៥ សម្តេចទ្រង់បានទទួលនាទីជាអធិបតីនៃថេរសភា គឺក្រុមជំនុំជាន់ខ្ពស់របស់សង្ឃ។

១៩៤៧ សម្តេចទ្រង់បានទទួលនាទីជាអនុប្រធានគណៈកម្មការវប្បធមិផ្នែកអក្សរ"ក" នៃគណៈកម្មការជាតិខាងការសិក្សា។

១៩៤៨ទ្រង់បានទទួលនាទីជាគណៈកម្មការធម្មវិន័យពិនិត្យការផ្សាយសៀវភៅសំរាប់សាលាធម្មវិន័យក្នុងព្រះរាជាណាចក្រ។

១៩៦១ រហូតមកសម្តេចទ្រង់ប្រោសមេត្តាទទួលនិមន្តរបស់សមាគមអ្នកនិពន្ធខ្មែរធ្វើជាព្រះប្រធាននៃការសម្ភាសន៏អក្សរសាស្ត្រដែលផ្សាយតាមវិទ្យុជាតិរៀងថ្ងៃសុក្រ។

១៩៦៨ទ្រង់ទទួលឋានៈជាព្រះប្រធានគណៈកម្មការពិនិត្យអត្ថបទផ្សាយជារឿងខាងប្រវត្តិសាស្ត្រខ្មែរ។

១៩៦៩ព្រះអង្គទទួលការតែងតាំងជាប្រធានគណៈកម្មការពិនិត្យនិងកំណត់អំពីវិន័យរបស់ទង់ជាតិខ្មែរ។

# រឿង ការមិនស្តាប់ ឪពុកម្តាយ

*ភាគទី២( ភាគបញ្ចប់)*

បន្ទាប់មកគាត់បង្រៀនវាពីរបៀបបណ្តែតខ្លួនតាមកំលាំងខ្យល់ហើយក្រលឹងនិងសំកាំងក្នុងខ្យល់។ ពួកគេហ្វឹកហាត់រួមគ្នារហូតទាល់តែអ៊ីការូស ចេះស្ទាត់។ ទីបំផុតក៏ពេលវេលាត្រូវចាកចេញមកដល់គឺពេលដែលមានខ្យល់បក់គ្រប់គ្រាន់សំរាប់ហោះហើរ។ ឪពុកនិងកូននាំគ្នាចងស្លាបទាំងពីរភ្ជាប់នឹងស្មាហើយរៀបចំហោះហើរត្រលប់ទៅផ្ទះវិញ «កូនទចងចាំអ្វីៗទាំងអស់ដែល ពុកបានប្រាប់ » ដេដាលូស និយាយទៅកាន់កូន « លើសពីនេះត្រូវចាំថាឯងមិនត្រូវហោះខ្ពស់ពេកឬទាបពេកទេបើឯងហោះទាបពេកទឹកសមុទ្រនឹងសាចទទឹកស្លាបឯងហើយធ្វើអោយស្លាបធ្ងន់ហួសស្ទះហើរលែងរួច។ បើឯងហោះខ្ពស់ពេកកំដៅថ្ងៃនឹងរំលាយក្រមួនដែលបិទស្លាបហើយស្លាបនឹងជ្រុះរោយរាយ ។ចូរហោះជិតពុកនោះកូននឹងមានសុវត្ថិភាព »រឹង! ពួកគេហោះឡើងកូនតាមពីក្រោយឪពុកហើយគេមើលឃើញទឹកដីប្រ - ទេសគ្រីតស្រុតចុះពីក្រោមពួកគេបន្តិចម្តងៗ។ ពេលគេហោះក្នុងអាកាសអ្នកភ្ជួរឈប់ភ្ជួរចោលភ្នែកសំលឹងពួកគេអ្នកគង្វាលនិងកម្មករឈរមើលគេដែរ ឯប្រជាជនរត់ចេញពីផ្ទះមកមើលរូបរាងគេទាំងពីរដែលហោះខ្ពស់ផុតចុងឈើ។ ពិតណាស់ពួកគេពិតជាអ្នកមានវិជ្ជាការខ្ពង់ខ្ពស់ប្រហែលឪពុកនិងកូនប្រុសដែលហោះតាមគ្នាពីក្រោយពីដំបូងការហោះហើរហាក់ដូចជាយ៉ាប់ណាស់សំរាប់ ដេដាលូស និង អ៊ីការូស ផ្ទៃមេឃល្វឹងល្វើយដាច់កន្ទុយភ្នែកធ្វើអោយពួកគេភាំងស្មារតីវង្វេងស៊ុងហើយសូម្បីតែការចោលកន្ទុយភ្នែកចុះក្រោមយ៉ាងរហ័សមួយរឹបក៏ធ្វើអោយខ្លួនក្បាលគេវិលវល់ក្រឡាប់ចាក់ដែរ។ ប៉ុន្តែបន្តិចម្តងពួកគេក៏ទំលាប់បានទៅនិងការហោះហើរក្នុងពពកហើយក៏បាត់ភ័យខ្លាច។ អ៊ីការូសទទួលអារម្មណ៏ថាខ្យល់បក់ស្ទួយរូបគេអោយអណ្តែតកាន់តែខ្ពស់ទៅខ្ពស់ទៅហើយ គេចាប់ផ្តើមដឹងខ្លួនថាដូចជាទទួលបានសេរីភាពមួយដែលគេមិនដែលមានពីមុនមកសោះ។ វាអោនមើលទៅខាងក្រោមយ៉ាងរំភើបក្រៃលែងឃើញកោះដែលវាហោះកាត់ឃើញប្រជាជននិងឃើញផ្ទៃសមុទ្រល្វឹងល្វើយពណ៌ខៀវស្រងាត់នៅពីក្រោមវារំលេចទៅដោយចំនុចពណ៌សៗនៃក្តោងនាវាទាំងឡាយ។ វាហោះឡើងកាន់តែខ្ពស់ទៅៗភ្លេចអស់ពាក្យព្រមាន របស់ឪពុកវា។ វាភ្លេចអ្វីៗទាំងអស់ក្នុងលោកនេះហើយនឹកឃើញតែម្យ៉ាងគឺការសប្បាយ « មកវិញមក » ដេដាលូស ស្រែកហៅកូនយ៉ាងក្រហល់ក្រហាយ«ឯងហោះខ្ពស់ពេកហើយចូរនឹកឃើញពីព្រះអាទិត្យ «!ចុះមក!ចុះមក! » ប៉ុន្តែអ៊ីការូសមិនបានគិតឃើញអ្វីទាំងអស់ក្រៅតែពីការរំភើបចិត្តនឹងភាពរុងរឿងអស្ចារ្យរបស់វាផ្ទាល់ ។វាចង់ហោះអោយកាន់តែខ្ពស់តាមតែវាអាចធ្វើបានដើម្បីបានទៅជិតស្ថានសួគ៌។ វាកាន់តែខិតជិតទៅកាន់ព្រះអាទិត្យហើយបន្តិចម្តងស្លាបវាក៏ទន់ជ្រាយពេលនោះស្លាបតូចៗក៏ចាប់ផ្តើមជ្រុះរោយរាយប៉ាយក្នុងខ្យល់ឯក្រមួនក៏រលាយអស់មួយរំពេច។ អ៊ីការូស ធ្លាក់ចុះក្រោមយ៉ាងលឿន។ វាទទះដៃវិចៗយ៉ាងញាប់តាមដែលអាចធ្វើបានប៉ុន្តែវាគ្មានស្លាបណាមួយទប់ខ្យល់បណ្តែតខ្លួនបានទៀតឡើយ។ វាស្រែកហៅឪពុកវាអោយជួយតែហួសពេលទៅហើយជាមួយនឹងសំរែកវាក៏ធ្លាក់ចុះពីកំពស់យ៉ាងខ្ពស់សន្លឹមចុះក្រោមហើយលិចទៅក្នុងសមុទ្របាត់រូបរាងក្រោមផ្ទាំងរលក ។ដេដាលូសហើរក្រលឹងឆ្វែលពីលើផ្ទៃសមុទ្រម្តងហើយម្តងទៀតប៉ុន្តែគាត់មិនឃើញអ្វីក្រៅតែពីស្លាបតូចៗដែលអណ្តែតលើផ្ទៃរលកគាត់ដឹងថាកូនគាត់ស្លាប់បាត់ហើយ។ ទីបំផុតសាកសពអ៊ីការូសក៏អណ្តែតឡើងលើផ្ទៃសមុទ្រហើយគាត់ក៏ប្រឹងប្រែងហើយឆាបយករូបវាពីផ្ទៃសមុទ្រ។

ជាមួយនឹងទឹកចិត្តធ្ងន់ពាប់នឹងឈឺផ្សារដេដា- លូស ហើរបីសាកសពកូនសន្សឹមៗទៅកាន់ច្រាំង។ ពេលទៅដល់ដីគោកគាត់ក៏បញ្ចុះសពកូនហើយកសាងប្រាសាទមួយឧទ្ទិសដល់កូន។ តាំងពីពេលនោះមកគាត់ព្យួរស្លាបទុកហើយលែងហោះហើរជារៀងរហូត។ ចប់

Fr. *ក្រិច អេង*

**ព្រាបសន្តិភាព** ទំនាក់ទំនង **JESUIT SERVICE CAMBODIA** # 96 St.592 BengkokII, Toulkork, PP.
Tel : 855 23 880 139/880455 Fax: 855 23 880 140 B.O.Box:880 Phnom Penh, CAMBODIA
www.jrscambodia.org, E-mail: jrscam@forum.org.kh